ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៦ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាព
## គណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ

◊◊◊◊+◊◊◊◊

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦.អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩ ស្ដីពីការបង្កើតគណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-លោកស្រី | **អេលៀង អៀវ** | នាយិកាក្រុមហ៊ុន I Ching (enterprise) | អនុប្រធាន |
| ៤-បណ្ឌិត | **ហ៊ុន ម៉ាណែត** | សមាជិកក្រុមប្រឹក្សាភិបាលអង្គការយុវតារា | សមាជិក |
| ៥-លោកស្រី | **អេង នេត្រា** | ប្រធានស្រាវជ្រាវផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦-លោក | **ណុះ ស្លេះ** | អ្នកសម្របសម្រួលមជ្ឈមណ្ឌលសម្របសម្រួលយុវជនមូស្លីមកម្ពុជា | សមាជិក |
| ៧-លោក | **ណៃ ឈួន** | មន្ត្រីកម្មវិធីទីភ្នាក់ងារអភិវឌ្ឍន៍របស់អូស្ត្រាលី | សមាជិក |
| ៨-លោក | **វ៉ាំង យុ** | នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា | សមាជិក |
| ៩-លោក | **ម៉ម អំណាត់** | ជំនួយការខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០-លោក | **អ៊ិន ចាន់នី** | ប្រធានប្រតិបត្តិធនាគារអេស៊ីលីដា (ACLEDA) | អគ្គលេខាធិការ |
| ១១-លោកស្រី | **ធីតា ឃិះ** | នាយិកាអង្គការសីលការ (Silaka) | អគ្គលេខាធិការរង |

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៣*

*-រាជកិច្ច* ✓

*-ឯកសារ-កាលប្បវត្តិ*